178/6

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៨៣

ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១២

សាលដីកា

លេខៈ ២៦៩

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០២ ក្រVIញ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៨៣ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទៈ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

-ជនជាប់ចោទឈ្មោះ [redacted] "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន កើតនៅភូមិក្រាំង ឃុំក្រាំងអំពិល ស្រុកកំពង់បាយ ខេត្តកំពត ទីលំនៅសព្វថ្ងៃភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] " ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។

-មានមេធាវីលោក [redacted]

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត។

-តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោ[redacted]ា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង៦និង២០នាទី មានប្អូនជីដូនមួយរបស់ប្រពន្ធខ្លួនឈ្មោះ [redacted]បានឃើញប្អូនប្រុសរបស់ខ្លួនឈ្មោះ[redacted]ស្លាប់ដេកពោបលើខ្សែលួសបន្លា ហើយនាំប្អូនជីដូនមួយម្នាក់ទៀតឈ្មោ[redacted]មកប្រាប់ខ្លួនថ[redacted]ាប់ហើយ ដោយសារឆក់ខ្សែភ្លើង។ ភ្លាមនោះខ្លួនក៏បានហៅឪពុកក្មេកខ្លួនឈ្មោះ[redacted]ឈ្មោះ [redacted]និងឈ្មោះ [redacted] ទៅដល់កន្លែងកើតហេតុឃើញប្អូនរបស់ខ្លួនឈ្មោះ[redacted]បានដេកស្លាប់ដោយយកដៃទាំងពីរកល់លើខ្សែលួស ក្បាលងើបឡើងលើឃ្លាតចម្ងាយ៤០ម៉ែត្រពីត្បូងផ្ទះខ្លួនបែរមុខសំដៅផ្ទះរបស់ឈ្មោះ [redacted] ដែលស្ថិតនៅក្រោយរបងផ្ទះឈ្មោះ[redacted]ហើយខ្លួនបានសែងសពមកផ្ទះ ឃើញមានរលាកកំភួនដៃចំនួន០៦កន្លែង រលាកក្រោមដៃឆ្វេង០១កន្លែង និងស្នាមរលាក់ដើមទ្រូង០៣កន្លែង។ សំណូមពរសុំទាមទារជម្ងឺចិត្តចំនួន៥.០០០ដុល្លារអាមេរិក។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពតថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅសព្វថ្ងៃភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ទោសពីមុនគ្មាន ឪពុកឈ្មោ[redacted] "ស" ម្តាយឈ្មោ[redacted]" ប្រពន្ធឈ្មោ[redacted]" មានកូន០១នាក់។

<u>ពិបទ:</u> ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

-បញ្ជូនជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២៨ ទៅជំនុំជម្រះតាមច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពត ដែលបានសម្រេច: -

-ឲ្យឈ្មោះ[redacted]ភេទប្រុស អាយុ២៨ឆ្នាំ រួចខ្លួនពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២ និងយោងតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខគូភាគី បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។



Scanned by CamScanner

78/4

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់[redacted]ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចនៃសេចក្តីសម្រេចសាលក្រមទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍ របស់លោក[redacted]ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពត ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចដែលបានសម្រេចឱ្យឈ្មោះ[redacted]ខ្លួនពីបទឃាតកម្មគិតទុកជាមុន។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា:តាមរបាយការណ៍នគរបាល ក៏ដូចជាចម្លើយសាក្សីអាចបញ្ជាក់បានថា ជនជាប់ចោទស្ថិតក្នុងវិមតិសង្ស័យនៅឡើយ ដូច្នេះមហាអយ្យការសុំឱ្យសភាព្រហ្មទណ្ឌតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពត ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០២ក្រVI"ញ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ របស់ឈ្មោះ[redacted] និងចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់[redacted]ជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ៥២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពត ចោលជាអសារបង់ ។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ (ដប់ឆ្នាំ) ពីបទ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

៤-បង្គាប់អោយជនជាប់ចោទឈ្មោះ[redacted] សងសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]។ សំណូមពរលើសពីនេះបដិសេធចោល។

៥-សម្រេចបន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]តាមនីតិវិធីច្បាប់។

៦-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ។ ទុកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់។



Scanned by CamScanner

78/3

-បានឃើញបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ[redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០២ក្រVI"ញ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសារណាការពារចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោ[redacted]

-បានឃើញសារណាតបចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted]

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់ជនជាប់ចោទ ឈ្មោ[redacted]ជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ០២ក្រVI"ញ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពារចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ ម៉ន ភារុណ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាតបចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ របស់ឈ្មោ[redacted]

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោ[redacted]មេធាវីការពារឱ្យជនជាប់ចោទនាពេលសវនាការថា: នៅថ្ងៃទី២០ ខែមីនា ឆនាំ២០០៩ កូនក្តីខ្ញុំបានទៅធ្វើការ ស្រាប់តែមានទូរស័ព្ទហៅឱ្យមកផ្ទះវិញ ពេលមកដល់ផ្ទះក៏ឃើញមនុស្សឈររមើលជនរងគ្រោះស្លាប់នៅក្បែររបងរបស់កូនក្តីខ្ញុំ ហើយបានចោទកូនក្តីខ្ញុំថា បានដាក់ខ្សែភ្លើងឱ្យឆក់ស្លាប់។ ផ្ទះកូនក្តីរបស់ខ្ញុំមានរបង៣ជ្រុង គ្មានរបងមុខផ្ទះទេតែនៅចំហ ហើយក៏មិនដែលមានបាត់របស់របរអ្វីដែរ, ទ្រព្យសម្បត្តិអ្វីទេ មូលហេតុអ្វីបានជាថាកូនក្តីខ្ញុំដាក់ខ្សែភ្លើងឆក់នោះ។ ចំពោះសមត្ថកិច្ចវិញបានបញ្ជាក់ថាពុំមានភាពស៊ីសង្វាក់គ្នាដើម្បីកំណត់បានថាឈ្មោ[redacted]ជាជនប្រព្រឹត្តបទល្មើសឡើយ។ ចំពោះតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានថា ពុំមានភស្តុតាងដែលថាកូនក្តីខ្ញុំដាក់ខ្សែភ្លើងដែលធ្វើឱ្យមនុស្សស្លាប់នោះទេ ដូចជាការសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់កូនក្តីខ្ញុំនោះផងដែរ។ កូនក្តីខ្ញុំមិនមែនជាជាងភ្លើងទេ គឺជាគ្រូបង្រៀន។

សំណូមពរ: សូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសម្រេចដោះលែងកូនក្តីខ្ញុំ។



Scanned by CamScanner

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាការពាររបស់គូក្តី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារអោយជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសលើជនជាប់ចោទ [redacted] ដាក់ពន្ធនាគារកំណត់១០ឆ្នាំ ពីបទ មនុស្សឃាតដោយចេតនា ដោយសំអាងលើចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី និងប្លង់រូបកន្លែងកើតហេតុចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ នោះជាការមិនត្រឹមត្រូវទេ ព្រោះថា តាមស្មារតីមាត្រា៣១២ (វិសមតិភាពរវាងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី) នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។ ក្នុងករណីនេះ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានតំលៃជាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទបានឡើយ ឯចម្លើយសាក្សីគ្រាន់តែបានឆ្លើយថាឃើញជនជាប់ចោទស្រាវខ្សែភ្លើងពណ៌សពីកន្លែងកើតហេតុ ដែលចម្លើយនេះមិនស៊ីសង្វាក់ទៅនឹងកំណត់ហេតុពិនិត្យកន្លែងកើតហេតុចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ របស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយសាក្សីឈ្មោះ [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា "នៅកន្លែងកើតហេតុមានបន្សល់ទុកនូវរនាំងរងារមួយនៅជាប់នឹងខ្សែលួសបន្លារបង និងមានស្នាមឈាមខ្មោចជាប់នឹងខ្សែលួសចងរង់តែន ទូរទស្សន៍..."។ ករណីនេះ មិនដឹងថាតើជនរងគ្រោះស្លាប់ដោយឆក់នឹងខ្សែភ្លើង រឺ ខ្សែលួសចងអង់តែនឡើយ ហើយក្នុងនីតិវិធីបណ្តឹងនេះ ក៏មិនទាន់មានភស្តុតាងណាមួយបង្ហាញឱ្យឃើញពីអត្ថិភាពនៃធាតុចេតនារបស់ជនជាប់ចោទក្នុងការភ្ជាប់ចរន្តអគ្គីសនីទៅនឹងខ្សែភ្លើង រឺ ខ្សែលួសផងដែរ។ ដូច្នេះសំអាងហេតុរបស់សាលាឧទ្ធរណ៍ពុំទាន់គ្រប់គ្រាន់ទេ ដូចនេះអាចត្រូវចាត់ទុកថាគ្មានសំអាងហេតុ ដែលជាមូលហេតុនៃបណ្តឹងសាទុក្ខស្របតាមស្មារតីមាត្រា៤១៩ ចំណុច៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned by CamScanner

78/1

-យល់ឃើញថា នាពេលសវនាការនេះ តំណាងមហាអយ្យការអមតុលាការកំពូលបានសន្និដ្ឋានថា ភស្តុតាងដាក់បន្ទុកស្ថិតក្នុងវិមតិសង្ស័យនៅឡើយ និងប្តឹងសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍។ ករណីនេះ សភាព្រហ្មទណ្ឌតុលាការកំពូលបានពិចារណាដូចខាងលើនេះ។

-យល់ឃើញថា គូភាគីត្រូវបានតុលាការកោះហៅត្រឹមត្រូវហើយ តែមិនចូលមកនាសវនាការនេះទេ ដូច្នេះតាមស្មារតីមាត្រា៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចជំនុំជម្រះបាន។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០២ក្រVI“ញ” ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះខុសនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់ជនជាប់ចោទ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ០២ក្រVI“ញ” ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៨៣ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសាជាថ្មី។

៤-សាលដីកានេះ ជំនុំជម្រះនាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៣
ជ.ប្រធានតុលាការកំពូល
អនុប្រធាន
[redacted]



Scanned by CamScanner